ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៨ លេខ ២ ខែមិថុនា ២០១៤ តម្លៃ ១.៥០០៛

# ចំណងទាក់ទងរវាងរដ្ឋ ជាមួយអ្នកស្រាវជ្រាវកម្ពុជា

## សេចក្ដីផ្ដើម

កម្ពុជា បានឆ្លងកាត់ការប្រែប្រួលធំៗមួយចំនួន បន្ទាប់ពីអង្គការសហប្រជាជាតិបានរៀបចំការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ ដែលបានត្រួសត្រាយផ្លូវ សម្រាប់ការផ្លាស់ប្ដូរជាច្រើននាពេលថ្មីៗនេះ។ កម្ពុជាបានចាកចេញពីស្ថានភាពមានសង្គ្រាម មកពង្រឹងសន្តិភាព, ពីសេដ្ឋកិច្ចបែបសង្គមនិយមតាមផែនការប្រមូលផ្ដុំ មកជាសេដ្ឋកិច្ចទីផ្សារសេរី, និងពីរបបឯកបក្ស មកជារបបប្រជាធិបតេយ្យសេរីពហុបក្ស, ប៉ុន្តែគុណភាពនៃការផ្លាស់ប្ដូរ ជំរុញដោយកត្តាខាងក្រៅទាំងនេះ នៅតែមាន ការលើកយកមកជជែកវែកញែកនៅឡើយ។ ការផ្លាស់ប្ដូរសំខាន់មួយក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះ គឺ កំណើនឯកសារសិក្សាស៊ីជម្រៅ និងការស្រាវជ្រាវស្ដីពី ប្រទេសកម្ពុជា ដោយអ្នកស្រាវជ្រាវនៅប្រទេសកម្ពុជា។ ប៉ុន្តែការស្រាវជ្រាវដោយអ្នកជំនាញការក្នុងស្រុកនេះ មានបរិមាណតិចតួច បើធៀបនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់។ ម្យ៉ាងទៀត ការរួមចំណែក និងការជះឥទ្ធិពលទៅលើគោលនយោបាយ និងដំណើរការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងរដ្ឋ នៅមានកម្រិតទាប ហើយសាធារណជនកម្ពុជា ក៏ទទួលបានព័ត៌មានតិចស្ដីពីបញ្ហាសង្គម សេដ្ឋកិច្ច និងនយោបាយ។



វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍ មានការចូលរួមពីអ្នកស្រាវជ្រាវកម្ពុជាជាង ២៥០នាក់ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវថ្មីៗ ផ្ដល់មតិយោបល់ត្រឡប់ និងពិចារណាលើសមិទ្ធផលនានា ព្រមទាំងគិតគូរបង្កើតអនុសាសន៍គោលនយោបាយសម្រាប់អនាគតរបស់ប្រទេសកម្ពុជា។ (ភ្នំពេញ ខែតុលា ឆ្នាំ២០១៤)

ការស្រាវជ្រាវនៅកម្ពុជា អនុវត្តដោយអ្នកស្រាវជ្រាវកម្ពុជាភាគច្រើនអាចរកបាន និងប្រើប្រាស់ ដោយអ្នកស្រាវជ្រាវបរទេស និងប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេស។ ក្នុងនេះ អ្នកស្រាវជ្រាវកម្ពុជា មានឧត្តមភាពច្រើនក្នុងការអនុវត្ត និងបកស្រាយនូវការសិក្សាស្រាវជ្រាវរយៈពេលវែង និងមានភស្តុតាងច្បាស់លាស់នៅក្នុងប្រទេសរបស់ខ្លួន ហើយបានរួមចំណែកយ៉ាងសំខាន់នៅក្នុងមជ្ឈដ្ឋានសិក្សាស្រាវជ្រាវនៅកម្ពុជា ដែលបច្ចុប្បន្នកំពុងតែគ្របដណ្ដប់ដោយជនបរទេស។ ប៉ុន្តែអ្នកស្រាវជ្រាវកម្ពុជា ក៏ត្រូវជួបនឹងបញ្ហាប្រឈមជាច្រើន ទាំងក្នុងការអនុវត្តការស្រាវជ្រាវជាក់ស្ដែង និងការដោះស្រាយជីវភាពក្នុងលក្ខណៈជាអ្នកស្រាវជ្រាវ។

អត្ថបទនេះ វាយតម្លៃពីស្ថានភាពនៃការស្រាវជ្រាវផ្នែកសង្គម និងឧបសគ្គ ដែលអ្នកស្រាវជ្រាវកម្ពុជាត្រូវប្រឈមមុខ ចាប់តាំងពីចុងបញ្ចប់សម័យខ្មែរក្រហម ដោយពិនិត្យពីចំណងទាក់ទងរវាងកិច្ចការនយោបាយផ្សេងៗ នៃការកសាងរដ្ឋ ហើយនិងទំនាក់ទំនងរវាងអ្នកស្រាវជ្រាវ ទៅនឹងរចនាសម្ព័ន្ធនៃអំណាចសព្វថ្ងៃ។ ការស្រាវជ្រាវពីមុនៗ បានរួមវិភាគទានដ៏មានតម្លៃដល់ការពិភាក្សាអំពី ស្ថានភាពនៃការស្រាវជ្រាវនៅកម្ពុជាក៏ពិតមែន ប៉ុន្តែច្រើនផ្ដោតតែទៅលើកត្តាស្ថាប័ន និងវប្បធម៌ ដើម្បីពន្យល់ពី

## មាតិកា

ចំណងទាក់ទងរវាងរដ្ឋ ជាមួយអ្នកស្រាវជ្រាវ ........................ ១
តើការទទួលបានឱកាសមានលក្ខណៈមិនស្មើភាពគ្នាប៉ុណ្ណានៅកម្ពុជា? ........................ ៦
ការផ្ដោតលើសមាសភាគបីនៃភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុនៅកម្រិតឃុំ និងដែនរងទឹកភ្លៀង... ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........................ ១៨
— ស្ថានភាពក្នុងប្រទេស........................ ២០
ផ្នែកស្រាវជ្រាវ ........................ ២៥
សេចក្ដីប្រកាសអំពីការផ្លាស់ប្ដូរថ្នាក់ដឹកនាំ វិទ្យាស្ថាន CDRI .. ២៨

---

អត្ថបទនេះ រៀបរៀងដោយ បណ្ឌិត អេង នេត្រា ជាអ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួលកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈនៃវិទ្យាស្ថាន CDRI។ គួរយោងឯកសារនេះថា៖ Dr Eng Netra (2014), "Engagement Between the State and Cambodian Researchers", *Cambodia Development Review,* 18(2):1-5.

ដំណើរការលូតលាស់អន់ខ្សោយ នៃការស្រាវជ្រាវផ្នែកសង្គម។ ទោះយ៉ាងនេះក្ដី អ្នកនិពន្ធបានព្យាយាមវែកញែកថា បញ្ហាផ្សេងៗ ដែលអ្នកស្រាវជ្រាវកម្ពុជា និងស្ថាប័នស្រាវជ្រាវនៅកម្ពុជា បាននិងកំពុងជួបប្រទះ វាជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងវិធីសាស្ត្រ និងតម្រូវការ ក្នុងកិច្ចប្រឹងប្រែងកសាងរដ្ឋក្នុងរយៈពេល ៣០ឆ្នាំកន្លងទៅនេះ។ ក្នុងទស្សនៈនេះ ការផ្លាស់ប្ដូរ និងទិសដៅទៅថ្ងៃអនាគត នៃការស្រាវជ្រាវផ្នែកសង្គមនៅកម្ពុជា មិនអាចស្វែងយល់បានឡើយ បើសិនគ្រាន់តែពិនិត្យពីបញ្ហាផ្នែកស្ថាប័ន និងបច្ចេកទេស ដោយមិនកំណត់ពីទិដ្ឋភាពផ្នែកនយោបាយ ដែលអ្នកស្រាវជ្រាវកម្ពុជាកំពុងជួបប្រទះនោះ។

## នយោបាយនៃការកសាងរដ្ឋ និងផលប៉ះពាល់ទៅលើអ្នកស្រាវជ្រាវកម្ពុជា

ដើម្បីពិនិត្យពីស្ថានភាពនៃការស្រាវជ្រាវ និងបញ្ហាដែលអ្នកស្រាវជ្រាវកម្ពុជាកំពុងប្រឈមមុខ គេចាំបាច់ត្រូវកំណត់ពីបរិបទដែលអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវត្រូវបំពេញតួនាទីរបស់ខ្លួននៅក្នុងដំណើរការកសាងរដ្ឋនៅកម្ពុជា បន្ទាប់ពីសម័យខ្មែរក្រហមបានបញ្ចប់។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាថ្មីមួយដឹកនាំដោយគណបក្សប្រជាជនបដិវត្តកម្ពុជា (ក្រោយមកប្ដូរឈ្មោះជា គណបក្សប្រជាជនកម្ពុជា) ត្រូវបានបង្កើតឡើងដោយអាជ្ញាធរវៀតណាម ដែលបានចូលមកក្នុងប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨។ រដ្ឋាភិបាលថ្មីត្រូវប្រឈមមុខនឹងបញ្ហាធំៗសម្បើម ក្នុងការកសាងឡើងវិញនូវប្រទេសមួយដែលមានសេដ្ឋកិច្ចបាក់បែកខ្ទេចខ្ទាំ, មានសង្គមមួយដែលពោរពេញដោយការតក់ស្លុត និង អំពើហិង្សា, មានប្រព័ន្ធស្ថាប័នរដ្ឋមួយដែលដាច់ដោចអស់, និងមានការកាត់ផ្ដាច់ឲ្យនៅឯកោពីលោកខាងលិច។

ក្នុងទសវត្សរ៍១៩៨០ ថ្នាក់ដឹកនាំកម្ពុជាបានផ្ដោតកម្លាំងលើការកសាងប្រព័ន្ធការិយាធិបតេយ្យឡើងវិញ, ការបង្កើតបណ្ដាញបក្សតាំងពីថ្នាក់មជ្ឈិមដល់ថ្នាក់មូលដ្ឋាន, និងការគ្រប់គ្រងលើគ្រោះថ្នាក់ នៃការបះបោរបង្កឡើងដោយកងទ័ពខ្មែរក្រហមដែលនៅសេសសល់ និងក្រុមសម្ព័ន្ធមិត្តដែលធ្វើប្រតិបត្តិការចេញពីទីជម្រកសុវត្ថិភាពក្នុងប្រទេសថៃ (Chandler 1991; Grant 1998)។ ក្នុងអំឡុងពេលនោះ រដ្ឋាភិបាលកម្ពុជាពឹងផ្អែកជាខ្លាំងទៅលើសមភាគីវៀតណាមរបស់ខ្លួន ទាំងសម្រាប់ការជួយមតិ ហិរញ្ញប្បទាន និងកិច្ចការពារផ្សេងៗ ក្នុងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋ។ ឯកសារ "បន្ទាប់ពីសម័យខ្មែរក្រហម" (*After the Khmer Rouge*) របស់ Evan Gottesman បានកត់ត្រានូវការយល់ដឹងខ្លះៗពីគោលនយោបាយ និងដំណើរការសម្រេចចិត្តនៅក្នុងរដ្ឋកម្ពុជានាពេលនោះ។ Gottesman បានបញ្ជាក់ថា ដំណើរការកំណត់គោលនយោបាយ មានលក្ខណៈជាការសម្រេចចិត្តធ្វើឡើងពីថ្នាក់លើបញ្ជាទៅថ្នាក់ក្រោម និងពុំមានការពិគ្រោះយោបល់ និងតម្លាភាពទេ ពោលគឺ មនុស្សមួយក្រុមតូចមួយទទួលបានសិទ្ធិអំណាចធំធេង និងដាច់ណាត់ធ្វើការសម្រេចចិត្ត ក្នុងបញ្ហានយោបាយ និងសកម្មភាព (Gottesman 2005:247-253)។ សំខាន់ជាងនេះទៀត ការសម្រេចចិត្ត និងគោលនយោបាយត្រូវបានធ្វើឡើងដើម្បីបម្រើ និងការពារ ផលប្រយោជន៍ថ្នាក់ដឹកនាំនៃរបបនោះ ជាជាងតាមការគិតគូរឲ្យបានស្របច្បាប់ និងសមហេតុសមផល។

ដំណើរការសម្រេចចិត្ត មិនមានលក្ខណៈប្រជាធិបតេយ្យនេះ ត្រូវបានជំរុញឡើងដោយថ្នាក់ដឹកនាំកំពូលៗរបស់កម្ពុជា ដែលនៅកាន់អំណាចមកទល់បច្ចុប្បន្ន ដោយបញ្ជាក់ហេតុផលថា វាចាំបាច់សម្រាប់ ស្ថានភាពប្រទេសនៅពេលនោះ។ មន្ត្រីនៅកម្រិតអនុវត្ត ជាពិសេសនៅថ្នាក់ក្រោមជាតិ បានទទួលសិទ្ធិអំណាចឲ្យធ្វើ "អ្វីដែលសក្តិសម" សម្រាប់តំបន់របស់ខ្លួន ឲ្យតែមន្ត្រីទាំងនោះ នៅរក្សាចំណងទាក់ទងជិតស្និទ្ធជាបុគ្គលជាមួយមេកើយខ្លួន និងបង្កើតចំណូលដ៏ចាំបាច់ តាមរយៈការរកកម្រៃក្រៅផ្លូវការ ដើម្បីផ្គត់ផ្គង់បណ្ដាញរបស់ពួកគេ។ តួយ៉ាង Gottesman (2005:233) បានបង្ហាញថា គោលនយោបាយតាមបែបសង្គមនិយមមួយចំនួនរបស់រដ្ឋាភិបាល ដូចជា គម្រោង ក៥[១] ជាដើម នៅទីបញ្ចប់ក៏បង្កើតបាន និងជួយទ្រទ្រង់ដល់ប្រព័ន្ធធំមួយ នៃបណ្ដាញខ្សែខ្នងឆ្លងកាត់បណ្ដាក្រសួង អាជ្ញាធរមូលដ្ឋាន និងកងទ័ព។ កិច្ចប្រឹងប្រែងជាផ្លូវការនៅពេលនោះ ផ្ដោតចម្បងទៅលើ ការបង្កើត និងទាញយកអត្ថប្រយោជន៍ផ្ទាល់ខ្លួនចេញពីគោលនយោបាយ និងសកម្មភាពរបស់រដ្ឋ ដោយធ្វើឲ្យខូចខាតដល់ការកសាង និងការប្រើប្រាស់សមត្ថភាពរដ្ឋក្នុងការសម្រេចចិត្ត និងការអនុវត្តគោលនយោបាយ ដោយផ្អែកលើបទបញ្ញត្តិច្បាប់ ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាជនទូទៅ (Ayres 2000; Hughes 2003)។ តាមគំនិតរបស់រដ្ឋាភិបាល ការអនុវត្តបែបនេះមានប្រសិទ្ធភាពល្អព្រោះវាមិនគ្រាន់តែជួយឲ្យរបបនេះរស់រានប៉ុណ្ណោះទេ ហើយថែមទាំងបម្រើផលប្រយោជន៍របស់បក្ស និងថ្នាក់ដឹកនាំបក្សដែលជាសមាជិករដ្ឋាភិបាលផងដែរ។

ស្ថានភាពដូចខាងលើ បានបន្តកើតមានក្នុងទូទាំងទសវត្សរ៍ ១៩៩០ និងរហូតមកទល់បច្ចុប្បន្ន ទោះបីមានអន្តរាគមន៍ពីអ្នកផ្ដល់ជំនួយអន្តរជាតិ ដែលបានចូលមកកម្ពុជាក្រោយពេលបញ្ចប់សង្គ្រាមត្រជាក់ក្នុងឆ្នាំ១៩៨៩ និងពីអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ដែលបានកាន់អំណាចរួមគ្នាជាមួយរដ្ឋាភិបាលកម្ពុជា ស្របតាមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ (Hughes 2003; Un 2005)។ នៅដើមទសវត្សរ៍១៩៩០ ទីប្រឹក្សាបច្ចេកទេសអន្តរជាតិ និងធនធានជាច្រើន បានហូរពីបស្ចិមប្រទេសចូលមកកម្ពុជា ក្នុងកិច្ចប្រឹងប្រែងកសាងប្រទេសឡើងវិញ។ ប៉ុន្តែកិច្ចប្រឹងប្រែងទាំងនោះត្រូវរាំងស្ទះជារឿយៗ ដោយសារបញ្ហានយោបាយក្នុងស្រុក។

ការសិក្សាពី "ការកសាងរដ្ឋនៅកម្ពុជា" ដោយ Sok Say ខាងផ្នែកព្រៃឈើ និងការនេសាទ បានរកឃើញថា ទោះបីជាសមត្ថភាពរដ្ឋនៅកម្ពុជា បានរីកចម្រើនយឺតៗតាំងពីឆ្នាំ១៩៩៣ មកក្ដី ក៏វានៅទន់ខ្សោយនៅឡើយក្នុងផ្នែកជាច្រើន ដោយសារ

---

[១] គម្រោង ក៥ បានអនុវត្តឡើងពីឆ្នាំ១៩៨៥-៨៩ ក្នុងលក្ខណៈជាកិច្ចប្រឹងប្រែងមួយមានប្រើកម្លាំងពលកម្មយ៉ាងច្រើន នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីការពារព្រំដែនកម្ពុជា-ថៃ តាមរយៈការកសាងលេណដ្ឋាន និងរបងឬស្សី និងការបង្កើតចំការមីន។

"វត្តមានពាសពេញ នូវការទាញយកប្រយោជន៍ពីរដ្ឋ ពីសំណាក់អាជីវករ និងប្រជាពលរដ្ឋជាទូទៅ, ការជ្រៀតជ្រែករបស់អ្នកនយោបាយ ទៅក្នុងការងាររការិយាធិបតេយ្យ និងស្ថាប័នរដ្ឋក្នុងនាម និងដើម្បីបម្រើផលប្រយោជន៍អតិថិជនរបស់ខ្លួន" (Sok 2012: 301)។ ស្រដៀងគ្នានេះដែរ សៀវភៅ "សហគមន៍ត្រូវពឹងពាក់គេ (Dependent Communities)" និពន្ធដោយ Caroline Hughes បង្ហាញពីរបៀបដែលជនមានអំណាចក្នុងស្រុកក្នុងបរិបទនៃប្រទេសទីម័រ និងកម្ពុជា (ដែលទើបបញ្ចប់ទំនាស់ និងត្រូវពឹងពាក់លើជំនួយ) បានខិតខំដោះស្រាយ និងបង្កើតយុទ្ធសាស្ត្រ ដែលហាក់ដូចជាអនុលោមតាមការទាមទាររបស់ម្ចាស់ជំនួយអន្តរជាតិ ខណៈដែលពួកគេនៅតែរក្សាលទ្ធភាពធ្វើសកម្មភាពបានតាមចំណង់ (Hughes 2009)។ Hughes បានបញ្ជាក់ថា ថ្នាក់ដឹកនាំកម្ពុជាសម្រេចបាននូវវត្ថុបំណងនេះតាមការផ្លាស់ប្តូរសិទ្ធិអំណាចសម្រេចចិត្តពិតប្រាកដ ពីស្ថាប័នរដ្ឋទៅឲ្យបុគ្គលស្មោះត្រង់ និងជាទីទំនុកចិត្តនៅក្នុងបណ្តាញផ្ទាល់របស់គណបក្សប្រជាជនកម្ពុជា (គបជ) ហើយនៅឆ្ងាយពីឥទ្ធិពល និងការចូលរួមរបស់ម្ចាស់ជំនួយអន្តរជាតិ និងសាធារណជនកម្ពុជា។ គោលនយោបាយ និងការសម្រេចចិត្ត ក៏ក្លាយជារបស់អ្នកមានទ្រព្យមានអំណាច និងជាបញ្ហាលាក់កំបាំង។

ជាលទ្ធផល ការធ្វើគោលនយោបាយ និងការចែករំលែកនូវគំនិតគិតគូរ មិនរំពឹងថានឹងកើតចេញមកពីជំនាញការនៅក្នុងវិស័យនេះឡើយ។ ការសម្រេចចិត្ត និងការបង្កើតគោលនយោបាយ គឺធ្វើឡើងទៅតាមបំណង និងចំណង់របស់ថ្នាក់ដឹកនាំនយោបាយកំពូលៗរបស់កម្ពុជា និងនៅក្នុងបណ្តាញខ្សែខ្នងរបស់គណបក្សប្រជាជនកម្ពុជា ជាជាងតាមការជជែកវែកញែកជាសាធារណៈ ពីសំណាក់អ្នកតំណាងក្រុមមនុស្សខុសៗគ្នា, ជំនាញការ និងនិន្នាការនយោបាយផ្សេងៗ។ ទោះបីគណបក្សប្រឆាំងដែលរួបរួមគ្នានោះ ទទួលបានសម្លេងឆ្នោតក្នុងចន្លោះពី ៣៩% ទៅ ៤៩% ក្នុងការបោះឆ្នោតថ្នាក់ជាតិចាប់តាំងពីឆ្នាំ១៩៩៣ មកក្តី ក៏ពួកគេនៅតែមានតួនាទីបន្ទាប់បន្សំប៉ុណ្ណោះក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ។

តាំងពីដើមរៀងមក ការសម្រេចចិត្តនៅកម្ពុជា តែងតែចំណុះឲ្យផលប្រយោជន៍នៃបណ្តាញខ្សែខ្នងរបស់របបគ្រប់គ្រង ដែលមានន័យថា អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ មានឱកាសនិងលទ្ធភាពតិចតួច ក្នុងការកំណត់របៀបវារៈសម្រាប់ការកសាងគោលនយោបាយ, ការចូលរួម និងការជះឥទ្ធិពលទៅលើដំណើរការសម្រេចចិត្ត។ រដ្ឋកម្ពុជា និងថ្នាក់ដឹកនាំនៅកម្ពុជាក៏មិនឲ្យតម្លៃដល់ ការចូលរួមចំណែក និងតួនាទីដែលអ្នកស្រាវជ្រាវក្នុងស្រុកអាចបំពេញបាន នៅក្នុងដំណើរការកសាងរដ្ឋ និងកសាងគោលនយោបាយ។ ប៉ុន្តែក្នុងនេះ គួរកត់សម្គាល់ជាសំខាន់ថា មានករណីលើកលែង និងការប្រែប្រួលខុសគ្នាមួយចំនួន ពីវិស័យគោលនយោបាយមួយទៅវិស័យមួយទៀត ទៅតាមចរិតលក្ខណៈ នៃវិស័យគោលនយោបាយទាំងនោះ និងផលប្រយោជន៍ចាក់ឫសនៅក្នុងនោះ។[២]

## "វប្បធម៌កម្ពុជា" ជាឧបសគ្គរាំងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជា?

វិធីសាស្ត្របែបមានមេកើយក្នុងការកសាងរដ្ឋនេះ បានជះឥទ្ធិពលខ្លាំងទៅលើទំនាក់ទំនងរវាងរដ្ឋ នឹងអ្នកស្រាវជ្រាវ និងគ្រឹះស្ថានសិក្សានៅកម្ពុជា ព្រមទាំងសមត្ថភាពអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវក្នុងស្រុក ដូចមានពិភាក្សានៅខាងក្រោម។ ឥទ្ធិពលពិតៗនៃវិធីសាស្ត្របែបនេះ មិនទាន់មានការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ នៅក្នុងឯកសារសិក្សាស្រាវជ្រាវមុនៗ ស្តីពីការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជា។ របាយការណ៍ថ្មីៗមួយរបស់អ្នកស្រាវជ្រាវកម្ពុជា និងបរទេសមួយក្រុមដែលទទួលការងារស្រាវជ្រាវពី សមាគមមជ្ឈមណ្ឌលស្រាវជ្រាវក្នុងស្រុក ហៅថា វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា គឺជាឧទាហរណ៍ដ៏ល្អមួយ។ នៅក្នុងបញ្ហាប្រឈមរបស់ស្ថាប័នស្រាវជ្រាវសាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវនៅកម្ពុជា របាយការណ៍នេះបានលើកពី "កង្វះថវិកា" "កង្វះគ្រឿងសម្រួលការ និងហេដ្ឋារចនាសម្ព័ន្ធ" និង "កង្វះវប្បធម៌ស្រាវជ្រាវ" (Kwok et al. 2010)។ របាយការណ៍បានបញ្ជាក់ម្តងហើយម្តងទៀតថា ឧបសគ្គដែលអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវនៅកម្ពុជា កំពុងប្រឈមមុខគឺ "កង្វះវប្បធម៌ស្រាវជ្រាវ" (Kwok et al.: 29, 34)។ ទស្សនៈដូច្នេះ ក៏ឃើញមាននៅក្នុងការសិក្សាដទៃទៀតដែលវាយតម្លៃពីស្ថានភាពនៃការស្រាវជ្រាវនៅកម្ពុជាដែរ (Pit and Ford 2004; Chet 2009)។ ជារឿយៗ "វប្បធម៌កម្ពុជា" ដែលគេពណ៌នាថាជានិន្នាការពីកំណើតក្នុងការទទួលយកនូវឋានានុក្រម, ការមិនអត់ឱនឲ្យមានអ្វីខុសប្លែកពីគេ, ភាពស្ពឹកស្រពន់ និងកង្វះចរិតចង់ដឹងចង់ឮនោះ គេបានយកមកប្រើប្រាស់ក្នុង ការសិក្សាពីមុនៗដើម្បីពន្យល់ពីចំណុចខ្សោយ នៅក្នុងដំណើរការធ្វើប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជា និងការកសាងសង្គមស៊ីវិល និងអភិបាលកិច្ចដោយមានការចូលរួម ជាដើម។

ឧបសគ្គផ្នែកវប្បធម៌នេះ ក៏គេបានអះអាងឡើងដែរ ក្នុងករណីផ្សេងទៀតនៅអាស៊ីអាគ្នេយ៍។ តួយ៉ាង Duncan McCargo បានវែកញែកថា កង្វះការស្រាវជ្រាវ និងការបោះពុម្ពផ្សាយនៅអាស៊ីអាគ្នេយ៍ ដោយអ្នកស្រាវជ្រាវក្នុងតំបន់វាផុសជាសំខាន់ចេញពី "វប្បធម៌សិក្សាស្រាវជ្រាវ" នៅក្នុងតំបន់ ដែលក្នុងនោះជំហរវិជ្ជាជីវៈ និងកេរ្តិ៍ឈ្មោះរបស់អ្នកស្រាវជ្រាវ "ជាប់ពាក់ព័ន្ធតិចតួចណាស់ ទៅនឹងការចូលរួមសកម្មក្នុងការស្រាវជ្រាវថ្មីៗ" (McCargo 2006:11)។ អ្នកសិក្សាស្រាវជ្រាវដទៃទៀតមិនឯកភាពតាមនេះទេ ហើយបានជជែកវែកញែកថា ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅក្នុងប្រទេសទាំងនោះ មានជាប់ទាក់ទងដោយផ្ទាល់ ទៅនឹងកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ, ការប្រើប្រាស់អំណាចរដ្ឋ និងគន្លងអភិវឌ្ឍន៍ជាក់លាក់នីមួយៗ (Zeleza 2002; Hadiz and Dhakidae 2005; Goh 2011)។ តួយ៉ាង Hadiz និង Dahkidae បានលើកថា "ភាពក្រខ្សត់" នៃការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គម នៅឥណ្ឌូនេស៊ី បណ្តាលមកពី "លក្ខណៈត្រូវអនុវត្ត

[២] Hughes and Conway (2003) បានកត់ត្រាពីដំណើរការសម្រេចចិត្ត និងកសាងគោលនយោបាយនៅកម្ពុជា និងបង្ហាញពីលទ្ធផលខុសៗគ្នានៃដំណើរការទាំងនោះ នៅក្នុងវិស័យគោលនយោបាយផ្សេងៗ រាប់តាំងពីវិស័យផ្តល់សេវាកម្ម រហូតដល់វិស័យត្រូវការធនធានច្រើន។

ជាក់ស្ដែងនៃវិទ្យាសាស្ត្រសង្គម ដែលបានក្លាយជាឧបករណ៍សម្រាប់បម្រើរបបការិយាធិបតេយ្យ" និងដែលរដ្ឋនៅតែបន្តអូសទាញមកដើម្បីជំរុញរបៀបវារៈជាក់លាក់នានា (2005:17)។

ដូចនៅកម្ពុជាដែរ "កង្វះធនធាន" "កង្វះជំនួយគាំទ្រផ្នែកស្ថាប័ន" និង "កង្វះហេដ្ឋារចនាសម្ព័ន្ធ" ប្រហែលអាចចាត់ទុកជាបញ្ហាបច្ចេកទេស និងបញ្ហាផ្នែកស្ថាប័នបាន ប៉ុន្តែលទ្ធភាពទទួលបានធនធាន, គ្រឿងសម្រួលការ ហេដ្ឋារចនាសម្ព័ន្ធ ហើយនិងរបៀបរបបផ្នែកស្ថាប័ន ដែលអំណោយផលដល់អាជីព និងសមត្ថភាពស្រាវជ្រាវ គឺសុទ្ធតែជាលទ្ធផលនៃការសម្រេចចិត្តផ្នែកនយោបាយ ថាតើនរណាគួរទទួលបានអ្វី នៅពេលណា និងតាមវិធីណា។ ជាក់ស្ដែង ការពង្រឹងសមត្ថភាពផ្នែកលើការស្រាវជ្រាវដ៏សំខាន់នេះ មិនមែនជាអាទិភាពរបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាចដែលមានភាពពេញច្បាប់ និងយុទ្ធសាស្ត្រផ្នែកនយោបាយបន្តផ្ដោតលើ "សមត្ថភាពរបស់ខ្លួនក្នុងការធ្វើអ្វីៗឲ្យបានសម្រេច" តាមរយៈអភិបាលកិច្ចបែបមេកើយ និងយុទ្ធសាស្ត្របែបប្រជាជននិយម នៃកម្មវិធីអភិវឌ្ឍន៍ជនបទមានប្រយោជន៍ច្រើនខាងនយោបាយរបស់ខ្លួននោះទេ។ ក្នុងបរិបទនេះ ប្រភេទនៃ ការចូលរួមចំណែក និងសមត្ថភាព ដែលរបបនេះចង់បាន គឺការកៀងគរប្រមូលធនធាន និងបញ្ជូនវាទៅបម្រើយគម្រោង ហេដ្ឋារចនាសម្ព័ន្ធ ដែលឧបត្ថម្ភដោយ គណបក្សប្រជាជនកម្ពុជា ដើម្បីជាថ្នូរនឹងការគាំទ្រផ្នែកនយោបាយ នៅតាមតំបន់ជនបទ។ ជាលទ្ធផល គឺ "អវត្តមានស្ទើរតែទាំងស្រុងនូវមូលនិធិរបស់រដ្ឋាភិបាល និងការឲ្យតម្លៃដល់ការស្រាវជ្រាវនៅកម្ពុជា (Chet 2009:161)។

រដ្ឋាភិបាល បានបង្កើតប្រព័ន្ធដ៏ល្អិតល្អន់ស្មុគស្មាញមួយនៃការផ្ដល់កិត្តិយស និងគោរម្យងារ ហើយប្រើវាដើម្បីផ្ដល់រង្វាន់ដល់បុគ្គលនៅក្នុងប្រព័ន្ធការិយាធិបតេយ្យ, យោធា, សង្គមស៊ីវិល, និងវិស័យអាជីវកម្ម ដែលសុខចិត្តគាំទ្រ និងរួមចំណែកជំរុញរបៀបវារៈរបស់រដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា។ តួយ៉ាង ការតែងតាំង និងតម្លើងឋានៈឲ្យសាកលវិទ្យាធិការរដ្ឋ និងបុគ្គលិកថ្នាក់ខ្ពស់ក្នុងស្ថាប័នសិក្សាស្រាវជ្រាវ ជាសេចក្ដីសម្រេចរបស់រដ្ឋាភិបាល ហើយវាជាប់ទាក់ទងតិចតួចនឹងលទ្ធផលការងារ ប៉ុន្តែជាប់ទាក់ទងច្រើននឹងទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេ និងការគាំទ្រអំពីមន្ត្រីរដ្ឋាភិបាលមានឋានៈខ្ពស់ (Chet 2009:159)។ ទោះបីសព្វថ្ងៃ មានការជ្រើសរើសយកអ្នកមានការអប់រំ និងបណ្ដុះបណ្ដាលល្អកាន់តែច្រើននាក់ បញ្ចូលទៅក្នុងប្រព័ន្ធការិយាធិបតេយ្យរបស់រដ្ឋក្ដី ក៏អ្នកទាំងនេះមានឥទ្ធិពលតិចតួចទៅលើការបង្កើត និងអនុវត្តគោលនយោបាយ និងសេចក្ដីសម្រេចផ្សេងៗ ពីព្រោះយុទ្ធសាស្ត្រនៃការជ្រើសតាំងនេះ គឺសំដៅធានាឲ្យមានភក្ដីភាព និងការគាំទ្រពីក្រុមអ្នកវិជ្ជាជីវៈ និងមានការអប់រំខ្ពស់។ ដោយសារមូលហេតុនេះ ការសិក្សាស្រាវជ្រាវដែលគេគិតថាមានលក្ខណៈរសើបខ្លាំង ឬក៏រដ្ឋមិនអាចទទួលយកបាន កម្រឃើញមានធ្វើ ឬបោះពុម្ពផ្សាយនៅកម្ពុជាណាស់។ ដូច្នេះគេត្រូវសង្កត់ធ្ងន់លើ ការស្រាវជ្រាវទាក់ទងនឹង គោលនយោបាយជាក់ស្ដែង អាចអនុវត្តបាន ជាជាងការស្រាវជ្រាវពីបញ្ហាស្នូល និងធ្វើការវិភាគស៊ីជម្រៅ។

***ការស្រាវជ្រាវ មិនមែនដើម្បីបញ្ជាក់ថា អ្នកស្រាវជ្រាវកម្ពុជាទាំងអស់គ្នា សុទ្ធតែត្រូវអាជ្ញាធរអូសទាញបាន ឬក៏នៅកម្ពុជា គ្មានការស្រាវជ្រាវស៊ីជម្រៅណាមួយ បានធ្វើឡើងនោះទេ។ តាមពិត គឺមាន ការស្រាវជ្រាវឯករាជ្យ និងស៊ីជម្រៅ ដែលអ្នកស្រាវជ្រាវកម្ពុជា បានធ្វើឡើងនៅក្រៅ ស្ថាប័នរដ្ឋ និងសាកលវិទ្យាល័យរដ្ឋ។***

## ការអូសទាញអ្នកស្រាវជ្រាវកម្ពុជាទៅក្នុងរដ្ឋ

អ្នកស្រាវជ្រាវកម្ពុជា មិនគ្រាន់តែត្រូវគេផាត់ចេញពីកិច្ចការខាងសេដ្ឋកិច្ច និងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគេអូសទាញបញ្ចូលទៅក្នុងប្រព័ន្ធការិយាធិបតេយ្យរបស់រដ្ឋ និងបណ្ដាញផ្ទាល់ខ្លួន របស់គណបក្សប្រជាជនកម្ពុជាទៀតផង។ Gottsman បង្ហាញថា អ្នកមានការអប់រំល្អ និងបញ្ញវន្តនានាត្រូវបានបង្ខិតបង្ខំ ឲ្យគោរពតាមបន្ទាត់នយោបាយរបស់រដ្ឋ និងគណបក្ស ហើយស្ថិតក្រោមការពិនិត្យតាមដានជាប់រហូតអំពីភក្ដីភាពខាងនយោបាយ (Gottesman 2005:348)។ ការអនុវត្តបែបនេះ នៅតែមានជានិច្ច ដរាបណាអំណាចសេដ្ឋកិច្ច និងនយោបាយ បន្តប្រមូលផ្ដុំនៅក្នុងកណ្ដាប់ដៃពួកថ្នាក់ដឹកនាំនៅកម្ពុជា និងបណ្ដាញដ៏ភក្ដីរបស់ពួកគេ នៅតាមលំដាប់ខ្ពស់ៗនៃរចនាសម្ព័ន្ធរបស់បក្ស (Heder 2005; Hughes and Kheang 2011; Pak 2011; Un 2011)។

## តួនាទី និងឥទ្ធិពលរបស់ម្ចាស់ជំនួយអន្តរជាតិ នៅលើការស្រាវជ្រាវផ្នែកសង្គមរបស់កម្ពុជា

ការពិភាក្សាដ៏សំខាន់ ពីស្ថានភាពដូចខាងលើនៃការស្រាវជ្រាវ មិនមែនដើម្បីបញ្ជាក់ថា អ្នកស្រាវជ្រាវកម្ពុជាទាំងអស់គ្នា សុទ្ធតែត្រូវអាជ្ញាធរអូសទាញបាន ឬក៏នៅកម្ពុជាគ្មានការស្រាវជ្រាវស៊ីជម្រៅណាមួយ បានធ្វើឡើងនោះទេ។ តាមពិតគឺមានការស្រាវជ្រាវឯករាជ្យ និងស៊ីជម្រៅ ដែលអ្នកស្រាវជ្រាវកម្ពុជា បានធ្វើឡើងនៅក្រៅស្ថាប័នរដ្ឋ និងសាកលវិទ្យាល័យរដ្ឋ។ ការសិក្សាស្រាវជ្រាវនោះ អាចអនុវត្តទៅបានដោយសារជំនួយទ្រទ្រង់ និងធនធាន ពីម្ចាស់ជំនួយអន្តរជាតិ ដែលដើរតួនាទីយ៉ាងសំខាន់ និងមានឥទ្ធិពលខ្លាំង ក្នុងការកំណត់អាទិភាពស្រាវជ្រាវ, ការកសាងសមត្ថភាពស្រាវជ្រាវ, និងការជំរុញឲ្យមានជាអនុសាសន៍គោលនយោបាយ និងការធ្វើសកម្មភាពឆ្លើយតបនឹងលទ្ធផលស្រាវជ្រាវ។

ឧទាហរណ៍លេចធ្លោមួយ គឺ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលបានកកើតឡើង

ក្នុងឆ្នាំ១៩៩០ ក្នុងលក្ខណៈជាអង្គការស្រាវជ្រាវឯករាជ្យពីការអភិវឌ្ឍ ដើម្បីផ្ដល់លទ្ធផលស្រាវជ្រាវខាងគោលនយោបាយស្ដីពីអាទិភាពនានាសម្រាប់ការអភិវឌ្ឍកម្ពុជា។ អ្នកស្រាវជ្រាវទាំង ៣៦រូប នៅ CDRI សុទ្ធតែមានសញ្ជាតិកម្ពុជា ហើយភាគច្រើនបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិត មកពីបរទេស ដែលបង្ហាញពីការផ្លាស់ប្ដូរយ៉ាងសំខាន់មួយ ក្នុងសមត្ថភាពស្រាវជ្រាវនៅកម្ពុជា។ អ្នកស្រាវជ្រាវមានការបណ្ដុះបណ្ដាលខ្ពស់ចំនួនច្រើននាក់ដូច្នេះ ជួយឲ្យ CDRI អាចធ្វើការសិក្សាស្រាវជ្រាវប្រកបដោយគុណភាពក្នុងផ្នែកជាច្រើន តាំងពី សេដ្ឋកិច្ច កសិកម្ម រហូតដល់អភិបាលកិច្ច និងកំណែទម្រង់វិស័យសាធារណៈ។ ក្នុងច្រើនឆ្នាំកន្លងទៅនេះ CDRI បានចេញផ្សាយយ៉ាងទូលំទូលាយនូវឯកសារ ស្ដីពី ស្ថានភាពនៃការអភិវឌ្ឍនៅកម្ពុជា និងបានដឹកនាំវេទិកាសាធារណៈជាច្រើននៅកម្ពុជា និងនៅក្នុងតំបន់ ដើម្បីធ្វើការពិភាក្សាជាសាធារណៈ អំពីអនាគតប្រទេសកម្ពុជា។ CDRI ជាវិទ្យាស្ថានឯករាជ្យ ហើយធ្វើការសិក្សាស្រាវជ្រាវដែលអាចមានលទ្ធផលទិតៀនដល់គោលនយោបាយ និងដំណើរការរបស់រដ្ឋាភិបាល ពីព្រោះវិទ្យាស្ថានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាជិកជាជនកម្ពុជាផង និងជនបរទេសផង។ CDRI រក្សាខ្ជាប់នូវឯករាជ្យភាព និងគុណភាពការងាររបស់ខ្លួន ព្រោះជាលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីទទួលបានមូលនិធិពីម្ចាស់ជំនួយអន្តរជាតិ ដែលបច្ចុប្បន្នជាប្រភពចំណូលចម្បង សម្រាប់ប្រតិបត្តិការ និងសកម្មភាពស្រាវជ្រាវរបស់វិទ្យាស្ថាន។

នាពេលថ្មីៗនេះ មានស្ថាប័ន និងមជ្ឈមណ្ឌលស្រាវជ្រាវមួយចំនួនទៀតបានកកើតឡើង ដើម្បីចាប់យកឱកាសល្អនៃកំណើនតម្រូវការការស្រាវជ្រាវ និងការប្រឹក្សាយោបល់ នៅកម្ពុជា។ ជាក់ស្ដែង សព្វថ្ងៃមានឯកសារច្រើនណាស់ (ទោះបីជាមានគុណភាពខុសគ្នាខ្លាំងយ៉ាងណាក្ដី) ដែលកំពុងផ្សព្វផ្សាយក្នុងវិស័យអាជីវកម្មផ្ដល់ការប្រឹក្សាយោបល់នេះ។ ការងារផ្ដល់ការប្រឹក្សាយោបល់ដ៏សម្បូរនៅកម្ពុជា ដែលសង្កត់ធ្ងន់លើការស្រាវជ្រាវគោលនយោបាយចំពោះមុខនោះ វាបានប៉ះពាល់គួរឲ្យកត់សំគាល់ទៅលើសមត្ថភាពស្រាវជ្រាវដែលមានតិចតួចស្រាប់ និងការកសាងសមត្ថភាពស្ថាប័ន។ អ្នកស្រាវជ្រាវដែលមានស្នាដៃល្អកំពុងត្រូវស្រូបចូលទៅក្នុងការងារផ្ដល់ការប្រឹក្សាយោបល់ ដែលមានប្រាក់កម្រៃខ្ពស់។ ទាំងស្ថាប័នស្រាវជ្រាវរដ្ឋ និងឯកជនក៏ត្រូវគេអូសទាញឲ្យផ្ដល់អាទិភាពខ្ពស់ទៅលើ "ការស្រាវជ្រាវផ្ដល់ការប្រឹក្សាយោបល់" ហើយកំណត់វាជាសកម្មភាពស្នូលមួយរបស់ខ្លួនដើម្បីអាចរស់រានបាន (Kwok al. 2010)។ បទពិសោធន៍ក្នុងប្រទេសដទៃទៀតបង្ហាញថា នៅពេលសមត្ថភាព និងរបៀបរបបស្រាវជ្រាវដោយម៉ត់ចត់ នៅមិនទាន់កសាងបានរឹងមាំនោះ ការពឹងផ្អែកខ្លាំង និងការសង្កត់ធ្ងន់ ទៅលើការស្រាវជ្រាវផ្ដល់ការប្រឹក្សាយោបល់ វាធ្វើឲ្យចុះខ្សោយដល់ គុណភាព និងសមត្ថភាពរបស់សាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវ ដើម្បីធ្វើការស្រាវជ្រាវក្នុងរយៈពេលវែង និងធ្វើការអភិវឌ្ឍសមត្ថភាព (Hadiz and Dhakidae 2005; McCargo 2006)។

## សេចក្ដីសន្និដ្ឋាន

អត្ថបទនេះ បង្ហាញពីឧបសគ្គធំៗដែលអ្នកស្រាវជ្រាវកម្ពុជាត្រូវប្រឈមមុខក្នុងការស្រាវជ្រាវនៅកម្ពុជា។ ការផ្លាស់ប្ដូរក្នុងនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលបានសង្កេតឃើញក្នុងប៉ុន្មានឆ្នាំថ្មីៗ បានបើកច្រកមួយចំនួនសម្រាប់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងសម្លេងទិតៀននៅពេលដែលអ្នកសិក្សាស្រាវជ្រាវកម្ពុជាទទួលបានការគាំទ្រ និងឱកាស ដើម្បីធ្វើការស្រាវជ្រាវដោយប្រយ័ត្នប្រយែង។ ជំហរដ៏គួរឲ្យសង្ឃឹម ប៉ុន្តែនៅទន់ខ្សោយរបស់អ្នកស្រាវជ្រាវកម្ពុជា ក្នុងការសិក្សាពីកម្ពុជា និងការសិក្សាលើឯកសារអន្តរជាតិ អាចផុសចេញពីឧបសគ្គផ្នែករចនាសម្ព័ន្ធ ដែលអ្នកស្រាវជ្រាវកម្ពុជាត្រូវប្រឈមមុខក្នុងការអនុវត្តការស្រាវជ្រាវជាក់ស្ដែង និងការបន្តអាជីពជាអ្នកស្រាវជ្រាវដ៏ម៉ត់ចត់។

ជនកម្ពុជាដែលមកធ្វើការស្រាវជ្រាវនៅកម្ពុជា ហើយចេះភាសាខ្មែរ និងយល់ដឹងច្បាស់ពីទំនៀមទម្លាប់ក្នុងស្រុក តែងមានឧត្តមភាពធំធេងក្នុងការប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗ។ អ្នកស្រាវជ្រាវកម្ពុជា មានលទ្ធភាពច្រើនជាងក្នុងការធ្វើឲ្យអ្នកផ្ដល់ព័ត៌មានកើនទំនុកចិត្ត ហើយនិយាយប្រាប់ដោយត្រង់ៗ និងងាយក្ដាប់បានជាង ពីអ្វីដែលកំពុងកើតមានជាក់ស្ដែង បើធៀបនឹងអ្នកស្រាវជ្រាវបរទេស ដែលត្រូវជួបការលំបាកផ្នែកភាសា និងមានការយល់ដឹងតិចជាង អំពីរបៀបរបបក្នុងស្រុក។ ប៉ុន្តែចំណុចនេះ អាចធ្វើឲ្យអាជ្ញាធរដែលព្យាយាមបិទបាំងសកម្មភាពរបស់ខ្លួននោះ កើតការសង្ស័យលើអ្នកស្រាវជ្រាវ។ ដោយហេតុថាថ្នាក់ដឹកនាំកម្ពុជាបន្តគ្របដណ្ដប់លើ និងការពារទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅរបស់ខ្លួន (តាមរយៈការប្រើប្រាស់បណ្ដាញផ្ទាល់ខ្លួន និងបណ្ដាញហិរញ្ញុប្បទានក្រុម) ក្នុងការកំណត់របៀបវារៈ និងធ្វើសេចក្ដីសម្រេចផ្សេងៗ ដូច្នេះហើយហិរញ្ញប្បទានរបស់រដ្ឋាភិបាល សម្រាប់ស្ថាប័នស្រាវជ្រាវមានតិចតួចណាស់ ហើយសម្លេងទិតៀន ក៏កម្រទទួលបានការគាំទ្រដែរ។ ក្នុងស្ថានភាពបែបនេះ ការស្រាវជ្រាវនៅកម្ពុជាទទួលបានហិរញ្ញប្បទានជាសំខាន់ពីជំនួយបរទេស និងអង្គការអន្តរជាតិ ហើយទំនងត្រូវបន្តពឹងផ្អែកលើជំនួយទាំងនេះ ក្នុងរយៈពេលវែងទៅមុខទៀត។

ស្ថានភាពនៃការស្រាវជ្រាវនៅកម្ពុជា មានការផ្លាស់ប្ដូរយឺតៗ។ បើធៀបនឹងម្ភៃឆ្នាំមុន ចំនួននិស្សិតកម្ពុជាដែលបញ្ចប់ការសិក្សាថ្នាក់ឧត្តម បានកើនឡើងយ៉ាងទៀងទាត់ ហើយក្នុងនោះ មានច្រើននាក់កំពុងធ្វើការស្រាវជ្រាវខាងផ្នែកសង្គម។ ទោះយ៉ាងណាក្ដី ទិសដៅទៅអនាគតនៃការស្រាវជ្រាវផ្នែកសង្គមនៅកម្ពុជា មិនមែនមានត្រឹមតែកំណើនចំនួនអ្នកស្រាវជ្រាវក្នុងស្រុក ដែលមានសញ្ញាប័ត្រអនុបណ្ឌិត និងបណ្ឌិតនោះទេ។ សំខាន់បំផុត គឺត្រូវមានការបង្កើត និងផ្ដល់ឲ្យអ្នកស្រាវជ្រាវក្នុងស្រុកនូវ បរិយាកាសសង្គម នយោបាយ និងសេដ្ឋកិច្ចអំណោយផលមួយ ដែលលើកកម្ពស់ការទទួលស្គាល់, ស្វ័យភាព និងការគិតគូរច្នៃប្រឌិតរបស់អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវនៅកម្ពុជា។

តទៅទំព័រ ១១

មូលហេតុមួយទៀត នៃការចែកចាយមិនបានល្អនូវឱកាសទទួលបានការថែទាំសុខភាព និងការអប់រំ។ កត្តាកំណត់ទាំងនេះ អាចកើតមានព្រមៗគ្នា។ ដូច្នេះហើយ គោលនយោបាយសម្រាប់ទប់ស្កាត់ និងកាត់បន្ថយវិសមភាពឱកាសផ្សេងៗ គួរផ្ដោតលើកត្តារួមចំណែកឲ្យបានសព្វគ្រប់ទាំងអស់។ ការដោះស្រាយបញ្ហាសេដ្ឋកិច្ច អាចជួយជំនះលើឧបសគ្គផ្សេងៗទៀតដែលជាប់ទាក់ទងដល់បញ្ហាលទ្ធភាពប្រើប្រាស់សេវា ដូចជា បញ្ហាភាពខុសគ្នាតាមតំបន់ ជាដើម។ ទាំងអស់នេះ សុទ្ធតែជាបញ្ហាដែលអ្នកបង្កើតគោលនយោបាយគួរលើកយកមកពិចារណា។

សូមអានឧបសម្ព័ន្ធនៅក្នុងអត្ថបទជាភាសាអង់គ្លេស។

## ឯកសារយោង


Paes de Barros, Ricardo, Francisco H.G. Ferreira, Jose, R. Molinas Vega and Jaime Saavedra Chanduvi (2009), "Measuring Inequality of Opportunities in Latin America and the Caribbean" (Washington, DC: World Bank)

Fields, S. Gary (2002), "Accounting for Income Inequality and its Change: A New Method, With Application to the Distribution of Earnings in the United States, http://digitalcommons.ilr.cornell.edu/articles/265/ (accessed 23 May 2014)

Hoyos, Alejandro and Ambar Narayan (2011), "Inequality of Opportunities among Children: How Much Does Gender Matter?" Background paper for the World Development Report 2012

Son, Hyun Hwa (2012), *Inequality of Human Opportunities in Developing Asia,* Asian Development Bank Economics Working Paper Series No.328 (Manila: ADB)

Vega, Jose Molinas, Ricardo Paes de Barros, Jaime Saavedra Chanduvi, Marcelo Giugale with Louise J. Cord, Carola Pessino and Amer Hasan (2010), "Do Our Children Have a Chance? The 2010 Human Opportunity Report for Latin America and the Caribbean", Conference Edition (Washington, DC: World Bank)


*តពីទំព័រ ៥* **ចំណងទាក់ទងរវាង...**

## ឯកសារយោង


Ayres, D. (2000), "Tradition, Modernity, and the Development of Education in Cambodia", *Comparative Education Review*, 44(4): 440-463

Chandler, D.P. (1991), *The Tragedy of Cambodian History: Politics, War, and Revolution since 1945* (New Haven, CT: Yale University Press)

Chet, C. (2009), "Higher Education in Cambodia", in Y. Hirosato and Y. Kitamura (eds.), *The Political Economy of Educational Reforms and Capacity Development in Southeast Asia* (Springer Science)

Goh, B.L.(ed.) (2011), *Decentring and Diversifying Southeast Asia Studies: Perspectives from the Region* (Singapore: Institute of Southeast Asian Studies)

Gottesman, E. (2005), *Cambodia after the Khmer Rouge: Inside Politics of Nation Building* (Chiang Mai: Silkworm Books)

Grant, C. (1998), *Cambodia Reborn? The Transition to Democracy and Development* (Washington, DC: Brookings Institute)

Hadiz, V.R. and D. Dhakidae (2005), *Social Science and Power in Indonesia* (Singapore: Equinox Publishing)

Heder, S. (2005), "Hun Sen's Consolidation: Death or Beginning of Reform?" *Southeast Asian Affairs:* 113-130

Hughes, C. (2003), *The Political Economy of Cambodia's Transition 1999-2001* (London: Routledge Curzon)

Hughes, C. (2009), *Dependent Communities: Aid and Politics in Cambodia and East Timor* (Ithaca, New York: Cornell University Press)

Hughes, C. and T. Conway (2003),"Understanding Pro-poor Political Change: The Policy Process in Cambodia" (London: Overseas Development Institute)

Hughes, C. and U. Kheang (2011),"*Cambodia's Economic Transformation:* Historical and Theoretical Frameworks", in C. Hughes and U. Kheang (eds.), Cambodia's Economic Transformation (Copenhagen: NIAS Press)

Kwok K., Chan S., Heng C., Kim S., Neth B. and Thon V. (2010), "Scoping Study: Research Capacities of Cambodia's Universities" (Phnom Penh: Cambodia Development Research Forum)

McCargo, D. (2006),"Rethinking Southeast Asian Politics", in C. Chou and V. Houben (eds.), *Southeast Asian Studies: Debates and New Directions* (Singapore: Institute of Southeast Asian Studies)

Pak K. (2011), "A Dominant Party in a Weak State: How the Ruling Party in Cambodia has Managed to Stay Dominant", PhD thesis, Australia National University, Canberra

Pit, C. and D. Ford (2004), "Cambodian Higher Education: Mixed Visions", in P.G. Altbach and T. Umakoshi (eds.), *Asian Universities: Historical Perspectives and Contemporary Challenge* (Baltimore, MA: Johns Hopkins University Press)

Sok S. (2012), "State Building in Cambodia", PhD thesis, Deakin University, Melbourne

Un K. (2005), "Patronage Politics and Hybrid Democracy: Political Change in Cambodia 1993-2003", *Asian Perspective,* 29(2): 203-230

Un K. (2011), "Cambodia: Moving Away from Democracy?" *International Political Science Review,* 32(5): 546-562

Zeleza, P.T. (2002), "The Politics of Historical and Social Science Research in Africa", *Journal of Southern African Studies,* 28(1): 9-23